**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ១៦៨ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់ការបង្កើតសាកលវិទ្យាល័យចេនឡា

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស / រកម / ០១៩៦ / ០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៣០៣ / ១២៩ ចុះថ្ងៃទី ៣១ មីនា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក. ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ. ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## ស ម្រេ ច

**មាត្រា ១** : ទទួលស្គាល់ការបង្កើតគ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា **សាកលវិទ្យាល័យចេនឡា** "Chenla University" សរសេរកាត់ជាភាសាខ្មែរ "ស.ច.ឡ" សរសេរកាត់ជាភាសាអង់គ្លេស "C.L.U"។ សាកលវិទ្យាល័យចេនឡា មានទីតាំងស្ថិតនៅអាគារលេខ ៤៣ ផ្លូវលេខ ២៣១ សង្កាត់ផ្សារដើមគរ ខណ្ឌទួលគោក រាជធានីភ្នំពេញ។ សាកលវិទ្យាល័យនេះ ស្ថិតនៅក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ២** : សាកលវិទ្យាល័យចេនឡា ធ្វើការបណ្តុះបណ្តាល កម្រិតបរិញ្ញាបត្ររង បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ លើមហាវិទ្យាល័យប្រាំ :

- មហាវិទ្យាល័យ សិល្បៈ មនុស្សសាស្ត្រ និងភាសា
- មហាវិទ្យាល័យ គណិតសាស្ត្រ និងវិទ្យាសាស្ត្រ
- មហាវិទ្យាល័យ វិទ្យាសាស្ត្រសង្គម
- មហាវិទ្យាល័យ វិទ្យាសាស្ត្រអប់រំ
- មហាវិទ្យាល័យ វិស្វកម្ម

សាកលវិទ្យាល័យនេះ ត្រូវរៀបចំកម្មវិធីសិក្សាលម្អិត តាមកម្រិត និងមុខជំនាញ ដើម្បីសុំការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា បន្ទាប់ពីចាប់ដំណើរការបាន ៦ (ប្រាំមួយ) ខែ។ ទៅអនាគតសាកលវិទ្យាល័យនេះ អាចបើកសាខាមហាវិទ្យាល័យ មុខជំនាញ ប្រភេទបណ្តុះបណ្តាលដទៃទៀត ឬប្តូរទីតាំងថ្មី ដោយរៀបចំសំណុំបែបបទ សុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ៣** : សាកលវិទ្យាល័យចេនឡា មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និងសម្រេចលើគោលនយោបាយ ផែនការអភិវឌ្ឍកម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត។ តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងជាក់ស្តែង នៃសាកលវិទ្យាល័យចេនឡា ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល នៃសាកលវិទ្យាល័យ និងមានការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ៤** : សាកលវិទ្យាធិការ មានភារកិច្ច :

- ទទួលខុសត្រូវនៅចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រងសាកលវិទ្យាល័យនេះ និងធានាឱ្យមានសុវត្ថិភាព សណ្តាប់ធ្នាប់សង្គម។
- គោរព និងអនុវត្តតាមការណែនាំ និងបទដ្ឋានដែលពាក់ព័ន្ធការងារបណ្តុះបណ្តាល របស់ក្រសួងអប់រំ យុវជន និងកីឡា និងរបស់រាជរដ្ឋាភិបាល សំដៅធានាគុណភាពអប់រំ។
- រៀបចំរចនាសម្ព័ន្ធគ្រប់គ្រង ស្របតាមការណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា។
- គោរពតាមកិច្ចសន្យា ដែលសាកលវិទ្យាល័យចេនឡា បានសន្យាចំពោះក្រសួងអប់រំ យុវជន និងកីឡា។
- ធ្វើរបាយការណ៍អំពីការងារបណ្តុះបណ្តាល មកនាយកដ្ឋានឧត្តមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា តាមការកំណត់។

- ធ្វើរបាយការណ៍អំពីការងារបណ្ដុះបណ្ដាល មកនាយកដ្ឋានឧត្ដមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា តាមការកំណត់។

**មាត្រា ៥ :** និស្សិត ដែលរៀនចប់កម្មវិធីសិក្សារបស់សាកលវិទ្យាល័យចេនឡា និងទទួលបានជោគជ័យ ក្នុងការប្រលងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រតាមកម្រិត និងឯកទេស ដែលបានសិក្សា។ សញ្ញាបត្រនេះ ត្រូវបានផ្ដល់ឱ្យដោយសាកលវិទ្យាល័យចេនឡា ហើយត្រូវបានទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណីសាកលវិទ្យាល័យចេនឡា បំពេញ និងអនុវត្តបានតាមគោលការណ៍ និងបទដ្ឋានក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ៦ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាកលវិទ្យាធិការនៃសាកលវិទ្យាល័យចេនឡា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

*កន្លែងទទួល :*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *ឯកសារ- កាលប្បវត្តិ*